ក

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រឹត្យ

១៥-១១-២០០២ ព្រះរាជក្រឹត្យ នស/រកត/១១០២/៣០៧ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជូន ឯកឧត្តមឧត្តមសេនីយ៍ទោ **សើរ កុសល** ទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា និងជាសមាជិកព្រឹទ្ធសភា ៣៣០១

១៦-១១-២០០២ - ព្រះរាជក្រឹត្យ នស/រកត/១១០២/៣០៨ ស្តីពីការដកហូតតួនាទីនិងមុខតំណែងរបស់ឯកឧត្តម **កុយ គឹមផន** ពីអនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន និង តែងតាំង ឯកឧត្តម **សំ សុខ** ជំនួសវិញ ៣៣០២

១៦-១១-២០០២ - ព្រះរាជក្រឹត្យ នស/រកត/១១០២/៣០៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាម សញ្ញាតូបនីយកម្មដល់លោក **លីន លន់** (LIN LUN) ដើមកំណើតចិន សញ្ជាតិអង់គ្លេស កើតនៅក្រុងហុងកុង ប្រទេសចិន ៣៣០៣

១៦-១១-២០០២ - ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១០ ស្តីពីការ តែងតាំង ឯកឧត្តម **អ៊ុក ទីឌុន** ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ៣៣០៤

១៦-១១-២០០២ - ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១១ ស្តីពីការ តែងតាំង ឯកឧត្តម **គង់ សារាជ** ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ៣៣០៥

១៧-១១-២០០២ - ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១២ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ចំពោះសព:

១-វីរសេនីយ៍ឯក **ចៅ សុវណ្ណ**

២-វីរសេនីយ៍ឯក **ឡឹក ចាន់ម៉ាត់**

៣-វីរសេនីយឯក **គឹម ទិន** ៣៣០៦

១៨-១១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១៣ ស្តីពីការ ប្តូរគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ទៅជាគ្រឿងឥស្សរិយយស **សម្តេចព្រះ មហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្សកុសុមនារីរ័ត្ន** ថ្នាក់ **មហាសេនា** ជូនដល់ឯកឧត្តម ០២រូប:

១- ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

២- ឯកឧត្តម **ទៀ បាញ់** ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ៣៣០៧

២២-១១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១២ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ នាយទាហាន

ជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម:

ក- ថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **អ៊ឹម ជាសុឃឿន**

២-ឧត្តមសេនីយ៍ត្រី **ឡុង ឫទ្ធីយ៉ា**

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី

វរសេនីយ៍ឯក **ខាំ ផាយ** ៣៣០៨

២២-១១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១៥ ស្តីពីការបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិត ៣៣០៩

២២-១១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១៦ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ុក ជាមី** ជា **ឧកញ៉ា** ៣៣១៩

២៣-១១-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១១០២/៣១៧ ស្តីពីការតម្លើងឋានៈស្មើរដ្ឋលេខាធិការ ជូនឯកឧត្តម **យឹម សារិទ្ធ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ៣៣២០

II- រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

២៧-១១-២០០២ - អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៣ ៣៣២១

២៧-១១-២០០២ - អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៣២៣

១៥-១១-២០០២ - អនុក្រឹត្យលេខ ៥៣១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៣២៥

២១-១១-២០០២ - អនុក្រឹត្យលេខ ៥៣២ អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ៣៣២៦

២១-១១-២០០២ - អនុក្រឹត្យលេខ ៥៣២ អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ៣៣២៦

២១-១១-២០០២ - អនុក្រឹត្យលេខ ៥៣៣ អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ៣៣២៧

២១-១១-២០០២ - អនុក្រឹត្យលេខ ៥៣៤ អនក្រ.តត ស្តីពីការជូនមេដាយ មុនីសារាភ័ណ្ឌ ៣៣២៨

២៦-១១-២០០២ - អនុក្រឹត្យលេខ ៥៣៥ អនក្រ.តត ស្តីពីការជូនមេដាយ ការងារ ៣៣២៩

២១-១១-២០០២ - អនុក្រឹត្យលេខ ៥៣៦ អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ៣៣៣០

២៧-១១-២០០២ - អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៣៣២

២៨-១១-២០០២ - អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត ស្តីពីការជូនមេដាយ សហមេត្រី ៣៣៣៣

២៨-១១-២០០២ - អនុក្រឹត្យលេខ ៥៣៩អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ ៣៣៣៤

២៨-១១-២០០២ - អនុក្រឹត្យលេខ ៥៤០ អនក្រ.តត ស្តីពីការជូនមេដាយ សុវត្ថារា ៣៣៣៥

២៨-១១-២០០២ - អនុក្រឹត្យលេខ ៥៤១ អនក្រ.តត ស្តីពីការជូនមេដាយ ការងារ ៣៣៣៧

ទំព័រ

២៨-១១-២០០២	- អនុក្រឹត្យលេខ ៥៤៤ អនក្រ.តត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ	៣៣៤៣
២៨-១១-២០០២	- អនុក្រឹត្យលេខ ៥៤៥ អនក្រ.តត ស្តីពីការជូនមេដាយ មុនីសារាភ័ណ្ឌ	៣៣៤៥
២៩-១១-២០០២	- អនុក្រឹត្យលេខ ៥៤២ អនក្រ.ពត ស្តីពីការជូនមេដាយ ស្ថាបនាជាតិ	៣៣៤៧
	២-សេចក្តីសម្រេច	
២០-១១-២០០២	- សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការផ្ទេរសិទ្ធ នៃរាជរដ្ឋាភិបាលកម្ពុជា	៣៣៤៨
២៨-១១-២០០២	- សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការផ្ទេរសិទ្ធ	៣៣៤៩
	III-ការងារបណ្តាក្រសួង	
	១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	
២២-១១-២០០២	- ប្រកាសលេខ ៧៥៤ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់សំណង់ផ្ទះសំបែង ដីធ្លីប្រជារាស្ត្រក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង	៣៣៥០
២៦-១១-២០០២	- ប្រកាសអន្តរក្រសួងលេខ ៨០២ សហវ.ប្រក ស្តីពីការបង្កើត និង តែងតាំង ភ្នាក់ងារបើកផ្តល់ សំរាប់បើកបៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅក្រសួងសាធារណការ និង ដឹកជញ្ជូន	៣៣៥២
	២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	
២៧-១១-២០០២	-ប្រកាសលេខ ២៦១ MoC/M2002 ស្តីពីស្ថានភាពរោងចក្រ SHELBY CAMBODIA CO., LTD. នៅកម្ពុជា	៣៣៥៤
២៩-១១-២០០២	ប្រកាសលេខ ២៦៥ MoC/M 2002 ស្តីពីការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ទំនិញ (Certificate of Origin) ជូនអង្គការក្រៅរដ្ឋាភិបាល (NGOs)	៣៣៥៦
២៩-១១-២០០២	ប្រកាសលេខ ២៦៧ MoC/M 2002 ស្តីពីការអនុវត្តនីសហវិមជ្ឈការរបស់ ក្រសួងពាណិជ្ជកម្ម នៅតាមបណ្តាខេត្ត-ក្រុង សំរាប់គ្រប់គ្រងរោងចក្រដែលនៅឆ្ងាយ	៣៣៥៨
២៩-១១-២០០២	ប្រកាសលេខ ២៦៨ MoC/M 2002 ស្តីពីការតែងតាំងសមាជិកទីប្រឹក្សា សភាពាណិជ្ជ កម្ម រាជធានីភ្នំពេញ	៣៣៦២
	៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	
២២-១១-២០០២	-ប្រកាសលេខ ៣៧៥ ប្រក.កសក ស្តីពីការអនុញ្ញាតអោយបង្កើតរោងសិប្បកម្ម ផលិតតុក្កតាកែច្នៃអំពីឈើក្នុងប្រុក របស់ក្រុមហ៊ុន **សុខ ឆាយ** អាហារ៍ណ នីហារ៍ណ	៣៣៦៤
	៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន	
៥-១១-២០០២	-ប្រកាសលេខ ២៥៩/០២ ព.មប្រក ស្តីពីការអនុញ្ញាតឱ្យកាសែត "សេរីភាពថ្មី" បន្តអាជ្ញាប័ណ្ណ បោះពុម្ពចែកផ្សាយដោយមានលោក **សោម ទីវ:** ជាចាងហ្វាងការផ្សាយ	៣៣៦៦

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣០៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមឧត្តមសេនីយ៍ទោ **សោី គុសល** អត្តលេខ០០០១៩២ ទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា និងជាសមាជិកព្រឹទ្ធសភា ។

មាត្រា២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ :៧៦៧ច.ល

ដើម្បីចម្លងចែក

៣រល-០៧-១១-០០៣៧៤

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣០៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដកហូតតួនាទី និង មុខតំណែងរបស់ឯកឧត្តម **កុយ គឹមផន** ពីអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

មាត្រា ២ : តែងតាំងឯកឧត្តម **សំ សុខ** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ជំនួសឯកឧត្តម **កុយ គឹមផន** ។

មាត្រា ៣ : រាល់បទប្បញ្ញត្តទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៧៧១ ចិ.ល

ដើម្បីចម្លងចែក

ការ-០២-១១-០០៣៧៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .- ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីន លុន** (LIN LUN) ដើមកំណើតចិន សញ្ជាតិអង់គ្លេស កើតថ្ងៃទី ០៧ ខែមេសា ឆ្នាំ ១៩៥៦ នៅក្រុងហុងកុង ប្រទេសចិន ។

មាត្រា២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ចករ

នរោត្តម សីហនុ

លេខៈ ២២៨ ច.ល

៣រល-០៥-១១-០០៣២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាំ ឌី តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/១១០២/៣១០

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០២

ត្រាស់បង្គាប់

មាត្រា១ .- ត្រូវបានតែងតាំងឯកឧត្តម អ៊ុក វីធុន ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

មាត្រា២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ .- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២៣០ ច.ល

ជម្រាបជូនចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០២

ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល

៣រល-០២-១១-០០៣២៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០២

ព្រះរាជក្រឹត្យ

យើង

នស/រកត/១១០២/៣១១

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែមិនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់មាត្រា១១៥ថ្មី និង១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ១៧៨/១១០២/ពស/ខល ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០២

ត្រាស់បង្គាប់

មាត្រា១ .- តែងតាំងឯកឧត្តម **គង់ សារាជ** ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម **ហង់ ជួន** ដែលទទួលមរណភាព ។

មាត្រា២ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២៣៣ ច.ល

៣១ណ. ០២-១១-០០៣២៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ១១ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] គាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣៧២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិត្តិយសបច្ឆាមរណៈចំពោះសព :

១- វរសេនីយ៍ឯក ចៅ សុវណ្ណ អត្តលេខ ០០០៥៨៣ នាយការិយាល័យក្រឡាបញ្ជី ស្ថាប័នអយ្យការយោធា

២- វរសេនីយ៍ឯក ឡឹម ទាន់ម៉ាន់ អត្តលេខ ០០០៣៧៩ នាយសេនាធិការរង យោធភូមិភាគពិសេស

៣- វរសេនីយ៍ឯក គីម ទិន អត្តលេខ ០០០៧៦២ នាយការិយាល័យទំនាក់ទំនងព្រំដែនវៀតណាម ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៤៤៦ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាន ម៉ានិ តាន់

៣រល-០២.១១.០០៣៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤០ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូន គ្រឿង-ឥស្សរិយយស

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្តូរគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ទៅជាគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសម នារីរ័ត្ន ថ្នាក់ មហាសេនា ជូនដល់ឯកឧត្តម ០២ រូប ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ ដូចមានរាយនាមខាងក្រោមនេះ :

១- ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

២- ឯកឧត្តម ឡៅ ធាញ់ ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

មាត្រា ២ : ចំណុច ក ក្នុងមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤០ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ លេខ:២៣១ច.ល

ពាល.០២.១១-០០៣៨៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ នាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣៦៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តម្លើងឋានន្តរសក្តិថ្នាក់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម

ក- **តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១- ឧត្តមសេនីយ៍ត្រី **ទឹម ជាសុឃៀន** អត្តលេខ ០០០១១៦ នាយសេនាធិការរង និងជានាយការិយាល័យទី៣ កងទ័ពជើងគោក

២- ឧត្តមសេនីយ៍ត្រី **ឈុំ ឫទ្ធីយ៉ា** អត្តលេខ ០០០១១៨ ទីប្រឹក្សាក្រសួងការពារជាតិ

ខ- **តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី**

វរសេនីយ៍ឯក **ខាំ ផាយ** អត្តលេខ ០០០៣៩៤ មេបញ្ជាការរង យោធភូមិភាគទី១

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ៤៧៣៦ច.ល

ការស-៦៧-១១-០០៣៣១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០២ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០០២

បានយកសេចក្តីគោរពថ្វាយ

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចេង

ឧសាដ៍ តាន់

mojdcac1

នស/រកត/១១០២/៣១៥

ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ១៩ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **សូ សឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ១៤ ចុះថ្ងៃទី ១៧-៣-៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

២. ទណ្ឌិតឈ្មោះ **ហ៊ុយ ចយ** ហៅ **ជ័យ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៦ ចុះថ្ងៃទី ០៧-១២ ៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៣. ទណ្ឌិតឈ្មោះ **ខ្មៅខៃ ឃាំងឃុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១២-៨-៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤. ទណ្ឌិតឈ្មោះ **ខ្មៅខៃ ឃាំងហ៊ុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១២-៨-៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥. ទណ្ឌិតឈ្មោះ **រិន ខ្លី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៧ ចុះថ្ងៃទី ២០-៧-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៦. ទណ្ឌិតឈ្មោះ **ខា ញាក** ហៅ **ខាយ ញាក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ចុះថ្ងៃទី២៤-៣-៩៧ របស់តុលាការខេត្តបាត់ដំបង។

៧. ទណ្ឌិតឈ្មោះ **សោម សម្បត្តិ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១៩-០១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៨. ទណ្ឌិតឈ្មោះ **ឆា ខាសនា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១៩-០១-៩៦ របស់តុលាការខេត្តបាត់ដំបង។

៩. ទណ្ឌិតឈ្មោះ **សែម សល់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៤-៣-៩៧ របស់តុលាការខេត្តបាត់ដំបង ។

១០. ទណ្ឌិតឈ្មោះ **សូ ហឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ១៩-១០-៩១ របស់តុលាការខេត្តបន្ទាយមានជ័យ។

១១. ទណ្ឌិតឈ្មោះ **ទេស សុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាច សាលក្រមលេខ ០៧ ចុះថ្ងៃទី ២៤-៦-៩២ របស់តុលាការខេត្តបន្ទាយមានជ័យ។

១២. ទណ្ឌិតឈ្មោះ **ឃួន ស៊ីណរាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាច សាលក្រមលេខ ០៤ ចុះថ្ងៃទី ២៣-៦-៩៤ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៣. ទណ្ឌិតឈ្មោះ **អ៊ុង គីមហួរ** ហៅ **លាង ហួរ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំតាមអំណាចសាលក្រមលេខ២០ចុះថ្ងៃទី០៨-០២-៩៥របស់តុលាការខេត្តបន្ទាយមានជ័យ។

១៤. ទណ្ឌិតឈ្មោះ **ផា ផយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី ០៨-០២-៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៥. ទណ្ឌិតឈ្មោះ **នាង សាវ៉ែន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៧ឆ្នាំ តាមអំណាចសាលដីកាលេខ ១៦៤ ចុះថ្ងៃទី ២២-០៨-៩៧ របស់សាលាឧទ្ធរណ៍។

១៦- ទណ្ឌិតឈ្មោះ **សូ រ៉ែន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយជីវិតតាម អំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៩-០៨-៩២ របស់តុលាការខេត្តសៀមរាប ។

១៧- ទណ្ឌិតឈ្មោះ **នក ហាប់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី ១៩-៨-៩៤ របស់តុលាការខេត្តកំពត ។

១៨- ទណ្ឌិតឈ្មោះ **ឯម សារ៉េត** ហៅ **កេត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ០២-០២-៩៥ របស់តុលាការខេត្តកំពត ។

១៩- ទណ្ឌិតឈ្មោះ **គង់ ថា** ហៅ **មឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ២៣-៥-៩៦ របស់តុលាការខេត្តកំពត ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ២៨ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១- ទណ្ឌិតឈ្មោះ **ឈិន ស្លា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាម អំណាចសាលក្រមលេខ ៣៤១ ចុះថ្ងៃទី ២៨-១១-៩៥ របស់តុលាការខេត្តបាត់ដំបង ។

២- ទណ្ឌិតឈ្មោះ **កែវ ម៉ាប់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩៩ ចុះថ្ងៃទី ១៣-១២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៣- ទណ្ឌិតឈ្មោះ **ឈឿន សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំតាមអំណាចសាលក្រមលេខ ៦៤ចុះថ្ងៃទី ១៩-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៤- ទណ្ឌិតឈ្មោះ **នុំ ប៊ុរ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ ចុះថ្ងៃទី ២៨-៣-៩៥ របស់តុលាការខេត្តបាត់ដំបង ។

៥- ទណ្ឌិតឈ្មោះ **ម៉ុន យ៉ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ២៣-០២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៦- ទណ្ឌិតឈ្មោះ **នីយ អឿម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ចុះថ្ងៃទី ២២-០១-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៧- ទណ្ឌិតឈ្មោះ **អ៊ុក រតនា** ហៅ ប្រុស ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ចុះថ្ងៃទី ១៩-៥-៩៧ របស់តុលាការខេត្តបាត់ដំបង ។

៨- ទណ្ឌិតឈ្មោះ **ទ្រី សុភាព** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ចុះថ្ងៃទី ០៦-០១-៩៨ របស់តុលាការខេត្តបាត់ដំបង ។

៩. ទណ្ឌិតឈ្មោះ **ហម ហាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំតាមអំណាចសាលក្រមលេខ ១៥៣ចុះថ្ងៃទី ០៥-០៧-៩៦ របស់តុលាការខេត្តបាត់ដំបង ។

១០. ទណ្ឌិតឈ្មោះ **សុខ ម៉ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាច សាលក្រមលេខ ៩២ចុះថ្ងៃទី ២៤-០៤-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១១. ទណ្ឌិតឈ្មោះ **ព្រហ្ម សារឿម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាច សាលក្រមលេខ ១៧ចុះថ្ងៃទី ២២-០២-៩៤ របស់តុលាការខេត្តបាត់ដំបង ។

១២. ទណ្ឌិតឈ្មោះ **ឈិច តឿ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១០-០១-៩៦ និងលេខ ៣៤ ចុះថ្ងៃទី ២០-៣-៩៧ របស់តុលាការខេត្តបាត់ដំបង ។

១៣. ទណ្ឌិតឈ្មោះ **ចិន ចន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាច សាលក្រមលេខ ០៧ ចុះថ្ងៃទី ០២-០២-៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៤. ទណ្ឌិតឈ្មោះ **ហង្ស សុខឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ០៩ ចុះថ្ងៃទី ០៦-០២-៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៥. ទណ្ឌិតឈ្មោះ **សុខ ស៊ីណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២២-៦-៩២ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៦. ទណ្ឌិតឈ្មោះ **ឌួន គឹមសៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ ចុះថ្ងៃទី ២៧-១០-៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៧. ទណ្ឌិតឈ្មោះ **ខាំ ស៊ាយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ២៤-៨-៩៤ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៨. ទណ្ឌិតឈ្មោះ **ខាំ សំរិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាច សាលក្រមលេខ ០២ ចុះថ្ងៃទី ១៨-០១-៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៩. ទណ្ឌិតឈ្មោះ **ច្រាក់ ស៊ុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១២-០៣-៩៦ របស់តុលាការខេត្តតាកែវ ។

២០. ទណ្ឌិតឈ្មោះ **គីក មឹក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០៤-៥-៩៥ របស់តុលាការខេត្តសៀមរាប ។

២១. ទណ្ឌិតឈ្មោះ **លី លួម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៨០ ចុះថ្ងៃទី ២៤-៨-៩៥ របស់តុលាការខេត្តសៀមរាប ។

២២. ទណ្ឌិតឈ្មោះ **អ៊ុង រតនា** ហៅ **លាង ថូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ ចុះថ្ងៃទី០៨-២-៩៥ របស់តុលាការខេត្តសៀមរាប ។

២៣. ទណ្ឌិតឈ្មោះ **យន់ យឹម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ ចុះថ្ងៃទី ២០-១០-៩៧ របស់តុលាការខេត្តសៀមរាប ។

២៤. ទណ្ឌិតឈ្មោះ **ឆន ស៊ុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ២០-៥-៩៦ របស់តុលាការខេត្តសៀមរាប ។

២៥. ទណ្ឌិតឈ្មោះ **ស៊ុំ សារឿន** ហៅ **ម៉ុក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១២ឆ្នាំ តាមអំណាចសាលដីកាលេខ ១២១ ចុះថ្ងៃទី ១៨-៩-៩៦ របស់សាលាឧទ្ធរណ៍ ។

២៦. ទណ្ឌិតឈ្មោះ **ពាង ចំរើន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ "ខ" ចុះថ្ងៃទី ១២-៨-៩៧ របស់តុលាការក្រុងភ្នំពេញ ។

២៧. ទណ្ឌិតឈ្មោះ **ខ្វៀង យ៉ាំងនីច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៥-១១-៩៧ របស់តុលាការខេត្តកំពត ។

២៨. ទណ្ឌិតឈ្មោះ **ម៉ែន ទ៉ាន់នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ២១-១០-៩៦ របស់តុលាការខេត្តកំពត ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ២៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **ទ៉ាន់ ច័យ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាច សាលដីកាលេខ ១៩៩ ចុះថ្ងៃទី ១១-៨-២០០០ របស់សាលាឧទ្ធរណ៍ ។

២. ទណ្ឌិតឈ្មោះ **ចាន់ គង់** ហៅ **ចាន់ ពៅ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ឆ្នាំ តាមអំណាចសាលដីកាលេខ ១៩៩ ចុះថ្ងៃទី ១១-៨-២០០០ របស់សាលាឧទ្ធរណ៍ ។

៣. ទណ្ឌិតឈ្មោះ **សេង សម្បត្តិ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៩ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ចុះថ្ងៃទី ២២-០២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៤. ទណ្ឌិតឈ្មោះ **យ៉ិន អ៊ីល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រម លេខ ១០៧ ចុះថ្ងៃទី ១៨-៥-៩៩ របស់តុលាការខេត្តបាត់ដំបង។

៥. ទណ្ឌិតឈ្មោះ **គន់ គាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៩ ចុះថ្ងៃទី ២១-១០-៩៧ របស់តុលាការខេត្តបាត់ដំបង ។

៦. ទណ្ឌិតឈ្មោះ **ខាំង សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៩-៦-៩៨ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៧. ទណ្ឌិតឈ្មោះ **ហ៊ិន សារ៉ន** ហៅ **ម៉ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ០៤-៨-៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៨. ទណ្ឌិតឈ្មោះ **មុត ស៊ីន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំតាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ៣០-៦-៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

៩. ទណ្ឌិតឈ្មោះ **តុខ ពិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី ៣០-១១-៩៩ របស់ តុលាការខេត្តបន្ទាយមានជ័យ ។

១០. ទណ្ឌិតឈ្មោះ **នួន ឈឿត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រម លេខ ០៨ ចុះថ្ងៃទី ១៤-៣-២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១១. ទណ្ឌិតឈ្មោះ **អ៊ែក ទី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ ចុះថ្ងៃទី០២-៤-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១២. ទណ្ឌិតឈ្មោះ **សុត សុខុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី២៤-៤-៩៨ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៣. ទណ្ឌិតឈ្មោះ **សំ ម៉ិនធឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី០៧-៦-៩៦ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៤. ទណ្ឌិតឈ្មោះ **សោខ ប្រុស** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ០៦ ចុះថ្ងៃទី ១២-០១-៩៥និងលេខ៣៨ ចុះថ្ងៃទី២៣-១២-៩៧ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៥. ទណ្ឌិតឈ្មោះ **ទុំ ឌុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រម លេខ០២ ចុះថ្ងៃទី ១២-០១-២០០០ របស់តុលាការខេត្តព្រៃវែង ។

១៦. ទណ្ឌិតឈ្មោះ **ជឹម ចាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រម លេខ ៦០ ចុះថ្ងៃទី ២០-៦-២០០១ របស់តុលាការខេត្តព្រៃវែង ។

១៧. ទណ្ឌិតឈ្មោះ **ហួត ទីរៈ** ហៅ រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ ចុះថ្ងៃទី ០២-៦-២០០០ របស់តុលាការខេត្តព្រៃវែង ។

១៨. ទណ្ឌិតឈ្មោះ **នុំ យន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ០៦-៧-៩៩ របស់តុលាការខេត្តសៀមរាប ។

១៩. ទណ្ឌិតឈ្មោះ **ដេត សារឿន** ហៅ **ខា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ ចុះថ្ងៃទី ០៦-៧-៩៩ របស់តុលាការខេត្ត សៀមរាប ។

២០. ទណ្ឌិតឈ្មោះ **ឡុន ឡុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៧ឆ្នាំ តាមអំណាចសាលក្រម លេខ ២៨ ចុះថ្ងៃទី ១០-៣-២០០០ របស់តុលាការខេត្តសៀមរាប ។

២១. ទណ្ឌិតឈ្មោះ **ឃោ លីណា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២៨-៣-២០០០ របស់តុលាការខេត្តសៀមរាប ។

២២. ទណ្ឌិតឈ្មោះ **កែន សេរីវ៉ាឌុធ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ " ង " ចុះថ្ងៃទី ១៩-៧-២០០១ របស់តុលាការក្រុងភ្នំពេញ ។

២៣. ទណ្ឌិតឈ្មោះ **ជុន សុភ័ក្ត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ង" ចុះថ្ងៃទី ២៧-៤-២០០១ របស់តុលាការក្រុងភ្នំពេញ ។

២៤. ទណ្ឌិតឈ្មោះ **ឡុប់ មឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ចុះថ្ងៃទី ២៧-៨-៩៩ របស់តុលាការខេត្តកំពត ។

២៥. ទណ្ឌិតឈ្មោះ **ចាន់ លឿង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៨ឆ្នាំ តាមអំណាចសាលក្រមលេខ៥៦ ចុះថ្ងៃទី ២៥-១១-៩៩ របស់តុលាការខេត្តកំពត ។

២៦. ទណ្ឌិតឈ្មោះ **មួង រ៉េត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ចុះថ្ងៃទី ២១-៧-៩៩ របស់តុលាការខេត្តកំពត ។

មាត្រា ៤ : ត្រូវបានលើកលែងទោសឱ្យទណ្ឌិតចំនួន ២៧ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះ ខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **កខ សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៨-១០-៩២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

២. ទណ្ឌិតឈ្មោះ **ម៉ីយ ហៀប** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៦ចុះថ្ងៃទី ០៩-៨-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៣. ទណ្ឌិតឈ្មោះ **ភាក់ ចាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ចុះថ្ងៃទី ២៩-៨-៩២ របស់តុលាការខេត្តបាត់ដំបង ។

៤. ទណ្ឌិតឈ្មោះ **ភាក់ ណាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣៧ចុះថ្ងៃទី ១០-៨-៩៣ របស់តុលាការខេត្តបាត់ដំបង ។

៥. ទណ្ឌិតឈ្មោះ **ស្រី សាឌុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ចុះថ្ងៃទី ០៤-៤-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៦. ទណ្ឌិតឈ្មោះ **លី ហួច** ហៅ **ម៉ៅ សុខុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ៦០ចុះថ្ងៃទី ១៧-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៧. ទណ្ឌិតឈ្មោះ **ខន ខុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ចុះថ្ងៃទី ១៧-៥-៩៤ របស់តុលាការខេត្តបាត់ដំបង ។

៨. ទណ្ឌិតឈ្មោះ **ថ៊ែន សឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៨ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ចុះថ្ងៃទី ០៤-៣-៩៧ របស់តុលាការខេត្តបាត់ដំបង ។

៩. ទណ្ឌិតឈ្មោះ **សុខ ឆុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ចុះថ្ងៃទី ២០-០១-៩៤ របស់តុលាការខេត្តបាត់ដំបង ។

១០. ទណ្ឌិតឈ្មោះ **រ័ត្ន មុនី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ ៦ខែ តាមអំណាចសាលដីកាលេខ ៣៣៣.៣៣៤.៣៣៧ ចុះថ្ងៃទី ១៦-១១-២០០១ របស់ សាលាឧទ្ធរណ៍ ។

១១. ទណ្ឌិតឈ្មោះ **ហេង ទ្រី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ៣០-៨-៩០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១២. ទណ្ឌិតឈ្មោះ **ម៉ុន សារឿន** ហៅ **ដារ៉ូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់៣ឆ្នាំ៦ខែតាមអំណាចសាលក្រមលេខ៥៦ ចុះថ្ងៃទី២១-៨-២០០០របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៣. ទណ្ឌិតឈ្មោះ **ទ៉ាន់ ឡុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី២៧-១២-២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៤. ទណ្ឌិតឈ្មោះ **ម៉ៅ ទិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ចុះថ្ងៃទី២៧-១២-២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៥. ទណ្ឌិតឈ្មោះ **ប៊ូ ហ៊ិន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី២៧-១២-២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៦. ទណ្ឌិតឈ្មោះ **សួន ខុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលក្រមលេខ៧៥ ចុះថ្ងៃទី២៧-១២-២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៧. ទណ្ឌិតឈ្មោះ **ញួន ខិះ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី១៨-០១-៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ។

១៨. ទណ្ឌិតឈ្មោះ **ងិម ហោ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៣ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ចុះថ្ងៃទី ១២-០៤-៩៤ របស់តុលាការខេត្តតាកែវ ។

១៩. ទណ្ឌិតឈ្មោះ **ផាន់ គា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៤ ចុះថ្ងៃទី ៦-៩-២០០០ របស់តុលាការខេត្តព្រៃវែង ។

២០. ទណ្ឌិតឈ្មោះ **នាង គា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៨ ចុះថ្ងៃទី ២២-៩-២០០០ របស់តុលាការខេត្តព្រៃវែង ។

២១. ទណ្ឌិតឈ្មោះ **សួង រ៉ាយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២ឆ្នាំ តាម អំណាចសាលក្រមលេខ ៨៤ ចុះថ្ងៃទី ០៧-៩-២០០១ របស់តុលាការខេត្តព្រៃវែង ។

២២. ទណ្ឌិតឈ្មោះ **ហ៊ឹម សម័យ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥៣ ចុះថ្ងៃទី ០៨-៦-២០០១ របស់សាលាឧទ្ធរណ៍ ។

២៣. ទណ្ឌិតឈ្មោះ **ជា សិទ្ធិ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ខែ តាមអំណាចសាលក្រមលេខ ១៣៦ ចុះថ្ងៃទី ២៧-៨-២០០១ របស់តុលាការខេត្តកំពង់ធំ និងសាលក្រមលេខ ២៣ "ដ" ចុះថ្ងៃទី០៩-៤-២០០២ របស់តុលាការក្រុងភ្នំពេញ ។

២៤. ទណ្ឌិតឈ្មោះ **យូ សុផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៧ឆ្នាំ តាមអំណាចសាលដីកាលេខ ៣១០ ចុះថ្ងៃទី ២៤-១០-២០០១ របស់សាលាឧទ្ធរណ៍ ។

២៥. ទណ្ឌិតឈ្មោះ **ស៊ុខ ឌី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ឆ្នាំ តាមអំណាចសាលដីកាលេខ ២៥៦ ចុះថ្ងៃទី ១៤-៩-២០០១ របស់សាលាឧទ្ធរណ៍ ។

២៦. ទណ្ឌិតឈ្មោះ **នូ សំអន** ហៅ **ឆក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ ៦ខែតាមអំណាចសាលក្រមលេខ ៣២ "គ" ចុះថ្ងៃទី ២១-៦-២០០០ របស់តុលាការក្រុងភ្នំពេញ ។

២៧. ទណ្ឌិតឈ្មោះ **ស៊ុច ស៊ុផាណារ៉ា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ តាមអំណាចសាលដីកាលេខ ៨០ "ង" ចុះថ្ងៃទី ២០-៨-២០០២ របស់សាលាឧទ្ធរណ៍ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៧៣៥ ច.ល

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០២

ករណ.០៧.១១-០០៣៣៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សៅ រ៉ានី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣១៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម អ៊ុក ដាមរី

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២៧២ ច.ល

ដើម្បីចម្លងចែក

៣រល.០៧.១១.០០៣៣៣

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០១/២១៣ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការតែងតាំងឯកឧត្តម ឃឹម សារិទ្ធ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានៈស្មើរដ្ឋលេខាធិការ ជូនឯកឧត្តម **ឃឹម សារិទ្ធ** ទីប្រឹក្សាផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២: តែងតាំងឯកឧត្តម **ឃឹម សារិទ្ធ** ជាអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បន្ថែមលើមុខងារជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា១ . ត្រូវបានបំពាក់ មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូន ឯកឧត្តម អស់លោក ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជួយប្រជារាស្ត្រ ដែលរងគ្រោះដោយសារគ្រោះរាំងស្ងួត និង ទឹកជំនន់ ឆ្នាំ ២០០២ ដូចមានរាយនាម ខាងក្រោម :

១-ឯកឧត្តម **ចន់ តុងអ៊ីវ** រដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២-ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋលេខាធិការ ក្រសួង សុខាភិបាល

៣-ឯកឧត្តម **សួស គង់** អនុរដ្ឋលេខាធិការ ក្រសួង អភិវឌ្ឍន៍ជនបទ

៤-ឯកឧត្តម **អ៊ិត ណូឌី** អនុរដ្ឋលេខាធិការ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥-ឯកឧត្តម **ហ៊ុន ណេង** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្វាយរៀង

៦-ឯកឧត្តម **ឡូយ សុផាត** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រចេះ

៧-ឯកឧត្តម **កែម ជុំនិមល** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត តាកែវ

៨-ឯកឧត្តម **ឆេង ឆន្តារ៉ា** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត កណ្តាល

៩-ឯកឧត្តម **ឡើង អ៊ី** ប្រធាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត កំពង់ចាម

១០-ឯកឧត្តម **ហ៊ឹម ឆែម** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១១-ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១២-ឯកឧត្តម **អ៊ុក ដាមរី** អនុប្រធានទី១ កាកបាទក្រហមកម្ពុជា

១៣-ឧត្តមសេនីយ៍ឯក **មាស ស៊ីម** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៤-ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៥-ឧត្តមសេនីយ៍ឯក **ជា តារា** នាយករងសេនាធិការចំរុះ មេបញ្ជាការ

១៦-ឧត្តមសេនីយ៍ឯក **អ៊ុច សីខាន់** មេបញ្ជាការ កងទ័ពជើងទឹក

១៧-ឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៨-ឧត្តមសេនីយ៍ឯក **ផាន់ ខួន** អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

១៩-ឧត្តមសេនីយ៍ទោ **ជឿង សុខណ្ណាថា** មេបញ្ជាការ យោធភូមិភាគ ២

២០-ឧត្តមសេនីយ៍ទោ **ហ៊ុយ ពិសិដ្ឋ** មេបញ្ជាការ កងឯកភាពអង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី

២១-ឯកឧត្តម **សេង ឡេង** ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី

២២-ឯកឧត្តម **ហេង តៃគ្រី** ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

២៣-លោក **ហង្ស សារឿន** អគ្គលេខាធិការរង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២៤-លោក **ប៊ូន លឹមហេង** ប្រធាន នាយកដ្ឋានផ្គត់ផ្គង់ហិរញ្ញកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី

២៥-លោក **អ៊ុយ សំអាត** ប្រធាននាយកដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយកាកបាទក្រហមកម្ពុជា

មាត្រា២ . រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការ គណៈរដ្ឋមន្ត្រី និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ✓
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ -ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៤៦.អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសំរិទ្ធស្ថាបនាជាតិ** ជូនសប្បុរសជន 0៤ គ្រួសារ ដែលបានបរិច្ចាគធនធាន ជួយកសាងអគារសិក្សា ០១ ខ្នង នៅសាលាបឋមសិក្សា ហ៊ុន សែន ចំពុះក្អែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដូចមានរាយនាមខាងក្រោម ÷

១-លោកស្រី **តាំង វិញ្ញាឆ្លិច** និង ប្អូន ថវិកាចំនួន ៤.000 USD

២-លោក **នួន ពូនម៉ឹង** និង អ្នកស្រី ថវិកាចំនួន ៤.000 USD

៣-លោកយាយ **តាំង ឆែគីម** និង បុត្រ ថវិកាចំនួន ៤.000 USD

៤-លោកយាយ **តាំង គីមឈី** និង ក្រុមគ្រួសារ ថវិកាចំនួន ៤.000 USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច ✓
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦១ សសរ

សេចក្តីសំរេច
ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ , ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមសន្និសីទអន្តរជាតិលើកទី ២ នៃគណបក្សនយោបាយនៅអាស៊ី នៅទីក្រុងបាងកក ចាប់ពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០២ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន នៃរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០២

<u>ចម្លងជូន</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៧ ស.សរ

សេចក្តីសំរេច
ស្តីពីការផ្ទេរសិទ្ធ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធជូនឯកឧត្តម **ឆាយ ថន** រដ្ឋមន្ត្រីក្រសួងផែនការ ជារដ្ឋមន្ត្រីស្តីទីក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០២ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **ឆាយ ថន** ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៥៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតម្លៃលើ ផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង

៛៛៛

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ លើសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ២៧៦៣ សហវ វស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ ។

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ដល់ សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង ។

ប្រការ ២ : គណៈកម្មការអន្តរក្រសួងនេះមានសមាសភាពដូចខាងក្រោម :

១.	ឯកឧត្តម **ញាណន ឡេង**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ប្រធាន
២.	លោក **ប្រាក់ ស៊ីហារ៉ា**	អភិបាលរងទី ២ ក្រុងព្រះសីហនុ	សមាជិក

៣. លោក **សំ បុរេ** អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៤. លោក **ខៀវ ពិសិដ្ឋ** ជានាយកគំរោង អភិវឌ្ឍន៍ទីរួមខេត្ត-ក្រុង ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

៥. លោក **ស៊ូ គុណសុខុឡន** ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

៦. លោក **ទូ ចាន់នី** មន្ត្រីគំរោងការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួយការ

ប្រការ ៣ : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រ ក្នុងគំរោងការកែលំអទីរួមខេត្ត-ក្រុង រួចធ្វើការវាយតំម្លៃឱ្យបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

ប្រការ ៤ : គណៈកម្មការនេះ មានសិទ្ធិបង្កើតអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិប្រើប្រាស់ការិយាល័យគោលនយោបាយ និង ផែនការ នៅនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន សំរាប់បំពេញការងារប្រចាំថ្ងៃ ។

ប្រការ ៥ : ក្រសួងសាធារណការ និង ដឹកជញ្ជូន , សាលាក្រុងព្រះសីហនុ , នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អ៊ុក រ៉ាប៊ុន

ចំលងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ដូចប្រការ ៥

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩០២ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០២

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើន និង កែសម្រួលប្រាក់ឧបត្ថម្ភបើកផ្តល់ សំរាប់បើក
បៀវត្ស និង ប្រាក់អត្ថប្រយោជន៍ក្នុងវិស័យសង្គមកិច្ច និង យុវជន
ជូនមន្ត្រីរាជការ នៅក្រសួងសាធារណការ និង ដឹកជញ្ជូន

ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

-បានឃើញ អនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញ ប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃ គណនេយ្យសាធារណៈ

-បានឃើញ លិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យ សាធារណៈ ។

-បានឃើញ តម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន ។

សម្រេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ត្រូវបើកផ្តល់តាមរយៈ "ភ្នាក់ងារបើកផ្តល់" ។

ប្រការ ២ : ត្រូវបានតែងតាំង :

-អ្នកស្រី **ចាន់ តារា** បុគ្គលិកការិយាល័យហិរញ្ញកិច្ច-ថវិកា នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ជាភ្នាក់ងារបើកផ្តល់ ។

-អ្នកស្រី **សុខ ខេមរា** ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : អ្នកស្រី **ចាន់ តារា** និង អ្នកស្រី **សុខ ខេមរា** ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើ នៅរតនាគារជាតិ ដើម្បីទទួលមូលនិធិ សំរាប់យកទៅបើកបៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវ ទទួលខុសត្រូវផ្ទាល់ចំពោះ ប្រាក់កាស និង មូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : អគ្គលេខាធិការ, នាយកខុទ្ទកាល័យ, ប្រធានរតនាគារជាតិ, ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញវត្ថុ, ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសាធារណការ និង ដឹកជញ្ជូន ព្រមទាំង អ្នកស្រី **ចាន់ តារា** និង អ្នកស្រី **សុខ ខេមរា** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ឃឹ តាំងលីម

កន្លែងទទួល :

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៧

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៧៩ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពី ការបិទទ្វាររោងចក្រ SHELBY CAMBODIA CO., LTD. នៅកម្ពុជា

*****

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០៤ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : ចាត់ទុករោងចក្រកាត់ដេរផលិតស្រោមដៃ **SHELBY CAMBODIA CO., LTD.** ដែលលែងមានដំណើរការ ហើយកម្មករត្រូវបានបញ្ឈប់ពីការងារ ថាបាន **បិទទ្វារជាស្ថាពរ** ។ រោងចក្រកាត់ដេរសំលៀកបំពាក់នេះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មនឹងត្រូវ

ឆ្លូតពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

ប្រការ ២ : ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

ប្រការ ៣ : នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. [illegible] MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពី : ការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin) ជូនអង្គការក្រៅរដ្ឋាភិបាល (NGOs)

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- ក្នុងគោលបំណងបង្កើនសន្ទុះនាំចេញផលិតផលក្នុងស្រុក និង ដើម្បីជួយសំរួលបែបបទនាំចេញផលិតផលសិប្បកម្មផ្សេងៗ ធ្វើអំពីសូត្រ . អំបោះ . ដែក . ថ្ម . កំប្លោក . ស្លឹកត្នោត . គ្រឿងចម្លាក់សម័យទំនើប . វត្ថុប្រើប្រាស់បន្ទាប់បន្សំ ។ល។ ឱ្យបានឆាប់រហ័ស

សំរេច

ប្រការ ១ : ដើម្បីអោយអង្គការក្រៅរដ្ឋាភិបាលមានសិទ្ធ ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញពីក្រសួងពាណិជ្ជកម្ម សំរាប់នាំទំនិញសិប្បកម្មរបស់ខ្លួនទៅបរទេសបាន អង្គការក្រៅរដ្ឋាភិបាល (NGOs) ត្រូវបង្កើតក្រុមហ៊ុនមួយជាលក្ខណៈសហគ្រាសឯកបុគ្គល ទទួលខុសត្រូវមានកំរិត ដោយប្រើប្រាស់ដើមទុនបានមកពីអង្គការក្រៅរដ្ឋាភិបាល រីឯប្រាក់ចំណេញត្រូវបានបង្វិលទៅអង្គការក្រៅរដ្ឋាភិបាលនោះទាំងស្រុងវិញ ។

ប្រការ ២ : បន្ទាប់ពីបានបង្កើតក្រុមហ៊ុននៅនាយកដ្ឋាននិតិកម្មរួចហើយ អង្គការក្រៅរដ្ឋាភិបាលត្រូវចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីទទួលបានសិទ្ធនាំចេញតាមរយៈប្រព័ន្ធ MFN/GSP (លើកលែងផលិតផលជាប់កូតា) ។

ប្រការ ៣ : ការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនេះ (C/O) ត្រូវបានលើកទឹកចិត្តជូនដោយមិនមានបង់កំរៃ ឬ សោហ៊ុយរដ្ឋបាលអ្វីឡើយ ក្នុងករណីផលិតផលនាំចេញមិនជាប់កូតា ។

ប្រការ ៤ : នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ៖

ចម ប្រសិទ្ធ

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- អង្គការក្រៅរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៦៦៧ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពី : ការអនុញ្ញាតឱ្យបើកចំនួនសាខាទីចាត់ការរបស់ក្រសួងពាណិជ្ជកម្ម នៅតាមបណ្តាខេត្ត-ក្រុង សំរាប់គ្រប់គ្រងរោងចក្រដែលនៅឆ្ងាយ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- យោងស្មារតីអង្គប្រជុំ " ច្រកចេញ-ចូលតែមួយ " នៃ ក.អ."ត.វ.ក" នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០២
- យោងស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០២
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣ តទៅ មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងដែលនៅឆ្ងាយ ចំនួន ០៤ គឺ ខេត្តស្វាយរៀង , ខេត្ត កំពង់ចាម , ខេត្តកំពង់ឆ្នាំង និង ក្រុងព្រះសីហនុ ត្រូវសហការណ៍ជាមួយមន្ត្រីជំនាញរបស់ក្រសួងដែលបានចាត់តាំងចំនួន ០៤ នាក់ ក្នុងមួយខេត្ត-ក្រុង ដើម្បីអនុវត្តប្រព័ន្ធសហវិមជ្ឈការ សំរាប់គ្រប់គ្រងរោងចក្រ ។

មន្ត្រីជំនាញនេះមានភារកិច្ចជួយបណ្តុះបណ្តាល និង ណែនាំអំពីគោលការណ៍ច្បាប់ប្រភពដើមទំនិញ (Rules of Origin) និង ច្បាប់ផ្សេងៗទៀតទាក់ទងនឹងការនាំចេញ ។

ប្រការ ២ : ក្រុមហ៊ុន ឬរោងចក្រអាចដាក់ពាក្យសុំរបស់ខ្លួននៅមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដោយផ្ទាល់ ហើយទទួលយកវិញនៅទីនោះដដែល ក្នុងរយៈពេល ៤៨ ម៉ោង ស្មើនឹង ០២ ថ្ងៃធ្វើការ ចំពោះឯកសារត្រឹមត្រូវ និង គ្រប់គ្រាន់ ។

ប្រការ ៣ : មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង មានភារកិច្ចរៀបចំឯកសារនៃការត្រួតពិនិត្យ ផលិតកម្មរោងចក្រ , បំរែបំរួលផលិតកម្ម , របាយការណ៍ត្រួតពិនិត្យទំនិញ និង ស្ថានការណ៍របស់រោងចក្រ ដោយបញ្ជូនឡើងមកក្រសួង តាមរយៈនាយកដ្ឋានជំនាញ ។

ប្រការ ៤ : ក្រៅអំពីខេត្ត-ក្រុង ដូចបានកំណត់ខាងលើ គឺនៅរក្សាស្ថានភាពការងារដដែល រហូតដល់ខេត្ត-ក្រុងឆ្ងាយៗទាំងឡាយនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីដំណើរការប្រព័ន្ធសហវិមជ្ឈការនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ ៥ : ចំពោះនិតិវិធីនៃការបញ្ជូនឯកសារ-ពត៌មានផ្សេងៗ នាយកដ្ឋានជំនាញ និងមន្ទីរពាណិជ្ជកម្ម ខេត្ត-ក្រុង ត្រូវពិនិត្យដោះស្រាយឱ្យបានល្អប្រសើរគត់ហ្មត់ រក្សាការសម្ងាត់ទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន ដើម្បីធានាដោតវាសនាអំពីអត្ថប្រយោជន៍ MFN/GSP សំរាប់កម្ពុជា និង ចៀសវាងការ រាំងស្ទះ ដោយប្រការណាមួយ ប៉ះពាល់ដល់ការនាំចេញរបស់ក្រុមហ៊ុន ឬ រោងចក្រ ។

ប្រការ ៦ : កែសំរួលនិតិវិធីមួយចំនួននៃការនាំចេញទំនិញ ដែលមានចែងក្នុងប្រកាសលេខ ០៦០ MoC/M 2002 ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២ :

ក- <u>ទំនិញនាំចេញតាមនាវា (By Sea) អាចនាំចេញបាន លុះត្រាមាន</u> :

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staffs Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

- ■ របាយការណ៍របស់មន្ត្រីនាយកដ្ឋានជំនាញនៃក្រសួងពាណិជ្ជកម្ម និង ឧស្សាហកម្ម
- ■ វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
- ■ តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន

ខ- ទំនិញដែលបាននាំចេញរួចហើយតាមនាវា (By Sea) ក្រុមហ៊ុន ឬ រោងចក្រ អាចសុំយក :

- ■ វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice)
- ■ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin)
- ■ អាជ្ញាប័ណ្ណនាំចេញ (Export License)

លុះត្រាមានឯកសារយោងដូចខាងក្រោមនេះ :

- ● វិញ្ញាបនប័ត្របញ្ជាក់បរិមាណទំនិញ (Certificate of Quantity)
- ● ប្រតិវេទន៍គយ និង រដ្ឋាករ (Customs' Declaration)
- ● អាជ្ញាតិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ● វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)

គ- ចំពោះទំនិញនាំចេញតាមយន្តហោះ (By Air) ក្រុមហ៊ុនត្រូវមានឯកសារភ្ជាប់ដូចខាងក្រោមនេះ :

- ● ឯកសារយោង (Airway Bill; Certificate of Quantity; Customs' Declaration) ដែលបាននាំចេញលើងមុន បន្ទាប់នៃការស្នើសុំថ្មី
- ● វិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម (Certificate of Processing)
- ● វិក័យប័ត្រទំនិញ (Invoice) ធ្វើដោយក្រុមហ៊ុន
- ● តារាងបញ្ជាក់ការវេចខ្ចប់ (Packing List) ធ្វើដោយក្រុមហ៊ុន
- ● កិច្ចសន្យាទិញ-លក់ (Sale Contract)
- ● ការបញ្ជាទិញ (Purchasing Order)

ប្រការ ៧ : នាយកខុទ្ទកាល័យ . អគ្គនាយកបច្ចេកទេស . អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ . ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម . ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស . ប្រធាននាយកដ្ឋានកាំកុងត្រូល . ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

File: Prakas on Decentralized Procedure for remote Industrial Outlets

ប្រការ ៨ : ប្រកាស និង សេចក្ដីជូនដំណឹង ដែលមានលក្ខណៈផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល :

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សាលាខេត្តស្វាយរៀង
- សាលាខេត្តកំពង់ចាម
- សាលាខេត្តកំពង់ឆ្នាំង
- សាលាក្រុងព្រះសីហនុ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- សមាគមរោងចក្រស្បែកជើងនៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

File: Prakas on Decentralized Procedure for remote Industrial Outlets

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៦៨ MoC / M 2002

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២

ប្រកាស

ស្តីពីការតែងតាំងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

. បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា .

- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី .

- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណា ចក្រកម្ពុជា .

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកស/០៦៩៥/០៣ ចុះថ្ងៃទី ២២. ០៦.១៩៩៥ ប្រកាសដែលអោយប្រើច្បាប់ស្តីពី សភាពាណិជ្ជកម្ម ។

- បានឃើញអនុក្រឹត្យ លេខ ៩៤ អនក្របក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៤២៣ អនក្រ.តត ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សមាជិកជ្រើសរើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សំរាប់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ អាណត្តិទី ២

<u>សំរេច</u>

<u>**ប្រការ**</u> **១** :តែងតាំង សមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ១៩ រូប ៖-

១- លោក វ៉ាន់ សូអៀង
២- លោក យាំ ស៊ុយសាង
៣- លោក Tan Sri Dato Soon Siew Hoong
៤- លោក ជាសៀម ឡាយ
៥- លោកឧកញ៉ា ស្រី ណាងឈាង
៦- លោក ស៊ីវ ថៃ
៧- លោក ដើរីង ឆាណាយវ៉ា

៨-	លោក	ការ	សាវុត្ថ
៩-	លោក	ថុម	គីមសុន
១០-	លោក	ចាន់	ហ៊ុយលួង
១១-	លោក	តាន់	ហាំងម៉េង
១២-	លោក	តូនី	តាន់ឌីហ្សុណូ
១៣-	លោក	កុក	ហ្សាក់
១៤-	លោក	ផៃ	ហុកឈួន
១៥-	លោក	អ៊ឹង	ហុងម៉េង
១៦-	លោក	អៀ	ជៀមហេង
១៧-	លោក	តាំង	ងួនសុង
១៨-	លោក	ភឹង	កាំង
១៩-	លោក	ឧកញ៉ា	ដួង ឈឺវ

ប្រការ ២ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ។

ចម_ប្រសិទ្ធ

កន្លែងទទួល

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

C.o b

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣៧៥ ប្រក.កសក

ប្រកាស

ស្តីពី

ការអនុញ្ញាតអោយបង្កើតរោងសិប្បកម្មផលិតតុក្កតាកែច្នៃអំពីឈើក្នុងស្រុក របស់ក្រុមហ៊ុន សុង ឆាយ អាហារ័ណ នីហារ័ណ

****

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញប្រកាសលេខ ០០៩២ ប្រក.កសក. ម ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម ស្តីពីការបង្កើត និងគ្រប់គ្រងរោងចក្រអារឈើ រោងចក្រកែច្នៃឈើ រោងអារឈើ រោងជាងឈើ សិប្បកម្មប្រើប្រាស់វត្ថុធាតុដើមជាផល- អនុផល ព្រៃឈើរបស់រដ្ឋ រដ្ឋចំរុះឯកជន សមូហភាព និងឯកជន ក្នុងទូទាំងរដ្ឋកម្ពុជា
- បានឃើញមតិយល់ព្រមរបស់ឯកឧត្តមអភិបាលខេត្តកណ្តាល តាមចំណារលេខ ៣៥២ សណ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០២ លើសំណើសុំបង្កើតសិប្បកម្មផលិតតុក្កតាកែច្នៃអំពីឈើក្នុងស្រុក របស់ក្រុមហ៊ុន សុង ឆាយ អាហារ័ណ នីហារ័ណ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០២
- តាមសំណើរបស់ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់

សំរេច

ប្រការ១: - អនុញ្ញាតអោយលោក **គៅ សុខ** ភេទប្រុស អាយុ ៣៣ ឆ្នាំ នាយកក្រុមហ៊ុន សុង ឆាយ អាហារ័ណ នីហារ័ណ បង្កើតរោង សិប្បកម្មផលិតតុក្កតាកែច្នៃអំពីឈើក្នុងស្រុក សំរាប់ធ្វើការនាំចេញទៅបរទេសដែលមាន :

- ទីតាំងនៅភូមិទួលតាចាន់ ឃុំទួលតាចាន់ ឃុំព្រែកឯង ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ។

C.o b

- ម៉ាស៊ីនចេរ្យឃ្មៀលធុនតូចប្រើដោយចរន្តអគ្គិសនី ចំនួន ០៦ គ្រឿង . ម៉ាស៊ីនខាត់រំលីងប្រើដោយម៉ូទ័រ ចំនួន ០៥ គ្រឿង
- សមត្ថភាពផលិតក្នុងមួយឆ្នាំ ២០ ម៉ែត្រគ្រីគុណជាប្រភេទឈើក្នុងស្រុក (ខ្នុរ . ដើមចាន់ . ដើមអំពិលទឹកបារាំង និង ឈើសំបកកេសចាស់ៗ) ។

ប្រការ២:- សាមីជនដែលបានទទួលការអនុញ្ញាតអោយបង្កើតរោងសិប្បកម្ម ត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌនៃបទបញ្ជាដូចខាងក្រោម:

ក-ត្រូវស៊ូរួលដល់មុខនាទីសមត្ថកិច្ចរុក្ខា-ប្រមាញ់ ចេញ-ចូល ធ្វើការត្រួតពិនិត្យសកម្មភាពរោងសិប្បកម្មគ្រប់ពេលវេលា ។

ខ- ផលិតផលឈើកែច្នៃដឹកជញ្ជូនចេញពីបរិវេណរោងសិប្បកម្ម ត្រូវមានលិខិតអនុញ្ញាតចេញដោយសមត្ថកិច្ចរុក្ខា-ប្រមាញ់ ។

គ- ត្រូវមានសៀវភៅបញ្ជីតាមដានឈើចេញ-ចូលរោងសិប្បកម្ម ។

ឃ- ត្រូវទទួលខុសត្រូវលើគ្រប់បទល្មើស ដែលកើតមានក្នុងបរិវេណរោងសិប្បកម្មរបស់ខ្លួន ។

ង- ការប្តូរឈ្មោះ ឬផ្ទេររោងសិប្បកម្មពីអ្នកគ្រប់គ្រងមួយ ទៅអ្នកគ្រប់គ្រងមួយទៀត ត្រូវហាមឃាត់ជាដាច់ខាត ។

ប្រការ៣:- ប្រកាសអនុញ្ញាតនេះត្រូវទុកជានិរាករណ៍ ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងករណីដែលយល់ឃើញថាជាការចាំបាច់ ឬ បានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ ។

ប្រការ៤:- អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្ម កសិកម្ម ប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធានការិយាល័យរុក្ខា-ប្រមាញ់ខេត្តកណ្តាល និង សាមីជនត្រូវទទួលបន្ទុករៀង ៗ ខ្លួន អនុវត្តប្រកាសនេះ ។

ប្រការ៥:- ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០២

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "

- ដូចប្រការ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ៧៩៥/០២ ព.ម (ស.ក)

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០២

ប្រកាស

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៧៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ២៨៦ /៩៦ ព.មប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ស្តីពីការអនុញ្ញាតអោយកាសែត " សេរីភាពថ្មី " ដំណើរការបោះពុម្ពចែកផ្សាយដែលមានលោក សោម វីរៈ ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតរបស់លោក សោម វីរៈ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២ ស្តីពីសំណើសុំបន្តអាជ្ញាបណ្ណ័របស់កាសែត "សេរីភាពថ្មី" ។

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យកាសែត " **សេរីភាពថ្មី** " បន្តអាជ្ញាបណ្ណ័បោះពុម្ពចែកផ្សាយដោយមានលោក **សោម វីរៈ** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ៣៤ ផ្លូវលេខ២១០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ២ : ប្រកាសរបស់ក្រសួងពត៌មានលេខ ២៨៦/៩៦ ព.មប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

ប្រការ៤ : ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ៣ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ៥ : អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានពត៌មាននៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយកាសែត "**សេរីភាពថ្មី**" ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ៦ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល១ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាជ្ញាប័ណ្ណលើសរយៈពេល៣ខែក្រសួងពត៌មាន ចាត់ទុកថា សាមីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

លូ លាយស្រេង

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពត៌មានកម្ពុជា "ដើម្បីជ្រាបជាពត៌មាន"
- សាមីខ្លួន